# រឿងព្រះមហោសថ

Tome II

Roeung - Preah Mohosoth

R. le 12-12-5

ARCHIVES NATIONALES DÉPÔT

INDOCHINE FRANÇAISE RÉGIE DU DÉPÔT LÉGAL

h-4
D-82



ថ្លៃ ៨ រ

ARCHIVES NATIONALES
REGIE DU DEPOT LEGAL
ARCHI... NALES
COTE 2U
B. 61. 593



ពេលមួយទៀតព្រះរាជាទ្រង់ឲ្យអាមាត្យយកពស់ញី ១, ឈ្មោល ១, ឲ្យយកទៅឲ្យសិរីវឌ្ឍសេដ្ឋីនឹងមហាជនទាំងពួងថាៈ មានព្រះបន្ទូលត្រាស់ថាៈ ឲ្យយើងនាំពស់ទាំងពីរមកឲ្យអ្នក ទាយគេពស់ណាញី, ពស់ណាឈ្មោល, សិរីវឌ្ឍសេដ្ឋីនឹងអ្នកស្រុកស្តាប់ហើយ ក៏សួរទៅ



ព្រះមហោសថៈទៀត មហោសថឃើញពស់នោះហើយ ទ្រង់ស្គាល់មួយរំពេច ដោយហេតុថា: ពស់ឈ្មោលនោះ ក៏មានកន្ទុយធំ ក្បាលធំ សមនឹងក្អែក ហើយមានខ្ទុតកនោះធំវិញ ឯពស់ញីនោះសោតមានកន្ទុយនោះតូចស្តួច មានខ្ទុតកនោះវែងក្អែកតូច ខ្ទុតកនោះគេបមិនកើតធំវិញទេ ហេតុនោះទើបព្រះពោធិសត្វដឹង ទើបប្រាប់ទៅអ្នកផងថា: ម្នាលអ្នកទាំងឡាយ នេះពស់ញី នេះពស់ឈ្មោលហើយនិយាយសារសព្វដូចបាននិយាយមកខាងលើនេះស្រាប់ ៗ ទើបពួកសេនាទៅទូលព្រះរាជាធិរាជតាមដំណើរ ព្រះរាជាស្តាប់ហើយមានព្រះទ័យសោមនស្សជាខ្លាំង ទើបប្រាប់ទៅអាចារ្យសេនកទៀត អាចារ្យសេនកនៅតែមិនទាន់ឲ្យយកមកដូចមុនទៀត ។

សម័យថ្ងៃមួយព្រះមហាក្សត្រាធិរាជ នឹងអាចារ្យទាំង ៤ ប្រើរាជអាមាត្យម្នាក់នាំពត៌មានទៅកាន់កន្លែងសិរីវឌ្ឍ មួយអន្ទើជាមួយនឹងមហាជនទាំងឡាយ ជាដ្បិតមានព្រះបន្ទូលដ៏ពិសេសត្រាស់បង្គាប់មកកាន់អ្នកឲ្យរកគោដុះស្នែងត្រង់ជើង មានបួដុះលើក្បាលស្រែកពេទ្កង់មួយរាត្រីបីដងឲ្យបាន បើរកគោដូច្នោះបានហើយឲ្យនាំទៅថ្វាយនោះក៏គ្មានទោសថាបើរកពុំបានទេនឹងត្រូវមានទោស ៗ សិរីវឌ្ឍសេដ្ឋីជាមួយនឹងអស់មហាជនទាំងឡាយពិចារណាមិនយល់សេចក្តីប្រស្នានោះឡើយ ក៏មកសួរព្រះមហោ-សថអ្នកប្រាជ្ញ ៗ ព្រះអង្គអាចពិចារណាប្រស្នានោះ ដោយប្រាជ្ញាទិព្វយល់មួយរំពេច ក៏ពោធិសត្វនិយាយប្រាប់ទៅថា: អ្នកទាំងឡាយចូរជ្រើស

វិសេសកមាន់មួយ ដ្បិតមាន់ខ្នាយនូវជើងលោកហៅថាស្នែង, មានសិរនៅលើលោកហៅថាបួ, វាតែងរងាវមួយយប់បីដងលោកហៅថាពេទ៌១ យប់បីដងវិញ. ពួកមហាជនឮដូច្នោះហើយក៏រកមាន់នាំទៅថ្វាយព្រះមហាក្សត្រិយ៍ស្ដេចក៏មានព្រះរាជហឫទ័យ ត្រេកអរយ៉ាងក្រៃលែង ។

មានរឿងមួយទៀតថា, ព្រះរាជាទ្រង់បង្គាប់ឲ្យសិរីវឌ្ឍសេដ្ឋី យកកែវវិលដូចគូថខ្ចៅ ដែលមានគេដោតខ្សែពីបុរាណ តែដាច់អស់ទៅឲ្យបញ្ចូលខ្សែថ្មីទៀត បើបញ្ចូលមិនបានព្រះអង្គនឹងដាក់ទណ្ឌកម្មជាទម្ងន់ ឯសិរីវឌ្ឍសេដ្ឋី នឹងមនុស្សទាំងអស់ មិនអាចហ្នឹងបញ្ចូលខ្សែក្នុងកែវនោះបានឡើយ ក៏បបួលគ្នាទៅកាន់សំណាក់ព្រះពោធិសត្វ ជំរាបតាមដំណើរសព្វគ្រប់ ព្រះអង្គក៏ពិចារណាដំណើរមួយរំពេច ទើបប្រាប់ទៅថា: ចុះអ្នកកុំព្រួយបារម្ភឡើយ ខ្ញុំនឹងបញ្ចូលខ្សែក្នុងកែវនេះឲ្យបានដោយងាយ ព្រះអង្គឲ្យយកទឹកឃ្មុំមកលាបត្រង់រន្ធកែវនោះទាំងសងខាង ហើយឲ្យវេញសូត្រថ្មីល្អ លាបទឹកឃ្មុំត្រង់ចុងសូត្រនោះ ហើយឲ្យបញ្ចូល ត្រង់រន្ធប្រហោងកែវនោះបន្តិច ទើបយកទៅដាក់ត្រង់រន្ធស្រមោច ៗ ឯស្រមោចទាំងឡាយ ដល់ធុំក្លិនទឹកឃ្មុំក៏ចេញមកពីរន្ធពាំនាំខ្សែសូត្រនោះ ទាញចូលទៅក្នុងរន្ធ លេចចុងខ្សែឯខាងម្ខាងវិញ ព្រះមហោសថ ធ្វើដូច្នោះហើយព្រះអង្គយកកែវនោះមកឲ្យយកទៅថ្វាយព្រះរាជា ៗ ទ្រង់ជ្រាបថា: ព្រះមហោសថជាអ្នកប្រាជ្ញអាចបញ្ចូលខ្សែក្នុងកែវបានដូច្នេះហើយ ក៏មានព្រះរាជហឫទ័យរីករាយជាពន់ពេក ។

សម័យមួយដាច់ខាងក្រោយមកទៀត ព្រះរាជាឲ្យយកគោឈ្មោល ឲ្យស៊ីសណ្ដែកនោះច្រើន ធ្វើឲ្យគោនោះហើមពោះធំក្រៃ ឲ្យសកស្នែងឲ្យខ្ចី យករមៀតជូតខ្លួនគោនោះឲ្យមានសម្បុរលឿងល្អ រួចឲ្យយកទៅឲ្យសិរីវឌ្ឍសេដ្ឋី ព្រមទាំងអ្នកស្រុក ប្រាប់ថា: ព្រះរាជាឲ្យយកគោនេះមក ដ្បិតគោនេះចាស់ផ្ទៃកើតកូនមិនរួចរាល់ពីរថ្ងៃហើយ ចូររក



ឆ្មបមើលគោនោះ បើរកមិនបាន ទ្រង់នឹងដាក់ទោសជាទម្ងន់ ៦ សិរីវឌ្ឍសេដ្ឋី នឹងអ្នកស្រុកគិតពិចារណា រកពុំឃើញ ក៏ទៅជំរាបដល់ព្រះមហោសថ ព្រះអង្គក៏ពិចារណាដូច្នេះថា: មានតែគិតតបប្រស្នាទៅវិញ ទើបព្រះអង្គឲ្យទៅហៅមនុស្សម្នាក់ដែលមានសំដីថ្មមាត់ អាចនិយាយការបានមក ព្រះអង្គក៏ប្រាប់ថា: អ្នកឯងចូរទៅកាន់ព្រះរាជនិវេសន៍ កាលបើដិតដល់ អ្នកឯងរំសាយសក់ចុះលើស្មា យកដៃគក់ទ្រូងស្រែកទ្រហោយំបើអ្នកណាសួរកុំស្តី បើព្រះរាជាសួរសឹមអ្នកឯងលើកដៃក្រាបថ្វាយបង្គំទូលថា បពិត្រព្រះសមតិទេព ឪពុកខ្ញុំព្រះអង្គ មានគភ៌ដំណាស់ល្មមនឹងប្រសូតកូនហើយ ឥឡូវប្រសូតពុំរួចរាល់ដល់ថ្ងៃ ឥតឆ្មបណាមើលបានឡើយ ខ្ញុំព្រះអង្គមានតែព្រះអង្គជាទីពឹងពុំនាក់ ឥឡូវនេះសូម ព្រះអង្គជួយយកកូនអំពីផ្ទៃឪពុកខ្ញុំផង ព្រះរាជាមុខជាមានព្រះរាជឱង្ការថា: អានេះឆ្កួតទេឬ អញមិនដែលឮប្រុសណា មានកូនដូចពាក្យប្រៃស្តែងនេះឡើយ បើដូច្នេះឯងក្រាបទូលវិញថា: បពិត្រព្រះនរបតី បើប្រុសមិនដែលមានប្រសូតកូនដូច្នោះ តើហេតុអ្វី? ក៏ព្រះអង្គឲ្យយកគោឈ្មោលទៅឲ្យសិរីវឌ្ឍសេដ្ឋី នឹងអ្នកស្រុក ឲ្យធ្វើគោនោះឲ្យប្រសូតកូន? បើឪពុកខ្ញុំព្រះអង្គមិនដែលមានប្រសូតកូន គោឈ្មោលក៏មិនដែលមានប្រសូតកូនដែរ ៗ បុរសនោះស្តាប់ព្រះមហោសថ ចាំសព្វគ្រប់ហើយ ក៏ទៅ

ឆ្លើយប្រស្នាជូនព្រះមហោសថផ្ដាំនោះឯង , ព្រះរាជាឮហើយសួរថា: អ្នកណា អាចរិះគិតប្រស្នាមកជូនយើង? បុរសនោះក្រាបទូលថា: ព្រះមហោសថអ្នកប្រាជ្ញ ព្រះរាជាក៏មានព្រះរាជហឫទ័យត្រេកអរក្រៃពេក ។

ដល់សម័យខាងក្រោយមក ព្រះរាជាបំណងល្បងមហោសថទៀត ក៏ប្រើរាជអាមាត្យឲ្យទៅប្រាប់សិរីវឌ្ឍសេដ្ឋីនិងអ្នកស្រុកទាំងអស់ថា ព្រះរាជាឲ្យដណ្ដាំបាយ តែហាមមិនឲ្យយករបស់ ៨ មុខគឺ: អង្ករ ១, ឆ្នាំង ១, ទឹក ១, ឧស ១, បង្ក្រាន ១, ភ្លើង ១, មិនឲ្យស្រីដណ្ដាំ ១, មិនឲ្យប្រុសដណ្ដាំ ១, បើបានបាយហើយ កុំឲ្យដើរតាមផ្លូវ ស្រាប់តែបានបាយថ្វាយព្រះអង្គតែម្ដង បើធ្វើដូច្នេះ ទើបរួចទោស បើមិនធ្វើដូចព្រះបន្ទូលនេះទេ ព្រះអង្គនឹងដាក់ទណ្ឌកម្មជាទម្ងន់ ។ ឯសិរីវឌ្ឍសេដ្ឋីនិងអ្នកស្រុកទាំងអស់ ក៏គិតរកប្រស្នានេះពុំឃើញឡើយ ទើបនាំគ្នាទៅជំរាបដល់ព្រះមហោសថ ព្រះអង្គក៏ពិចារណាដឹងមួយរំពេចទើបប្រាប់ថា: អ្នកទាំងឡាយកុំភ័យអ្វី ប្រស្នានេះងាយទេតើ! ដែលស្ដេចមិនឲ្យយកអង្ករនោះគឺ: ឲ្យយកស្រូវស្រងែវិញ, ដែលមិនឲ្យយកទឹកនោះ គឺឲ្យយកសន្សើមវិញ, ដែលមិនឲ្យយកឆ្នាំង គឺយកខ្ទះវិញ, ដែលមិនឲ្យយកបង្ក្រានគឺឲ្យយកឈើបោះធ្វើជាពាវិញ ។ ដែលមិនឲ្យយកភ្លើងគឺឲ្យរៀរភ្លើងប្រក្រតី ឲ្យយកឬស្សីមកពួតយកភ្លើងជាថ្មីវិញ, ដែលមិនឲ្យយកឧសគឺឲ្យយកស្លឹកឈើមកដុតវិញ, ដែលមិនឲ្យប្រុសឬស្រីដណ្ដាំនោះ

គឺឲ្យមនុស្សខ្មើយដណ្ដាំវិញ, ដែលមិនឲ្យដើរតាមផ្លូវ គឺឲ្យដើរកាត់តម្រាយជើងដើរ! សិរីវឌ្ឍសេដ្ឋីទឹងមនុស្សទាំងអស់ ក៏ខ្វល់ខ្វាយធ្វើតាមបង្គាប់ រួចហើយក៏យកទៅថ្វាយព្រះរាជា ។ ឃើញដូច្នោះហើយក៏សួរថា: អ្នកណាអាចកាត់ប្រស្នានេះ អ្នកបម្រើក្រាបទូលថា: . ព្រះមហោសថ ព្រះរាជាក៏មានព្រះទ័យសោមនស្សជាពន់ពេក ។

មានសម័យក្រោយមក ព្រះរាជាល្បងព្រះមហោសថទៀត ទ្រង់ក៏ប្រើរាជអាមាត្យ ឲ្យនាំដំណឹងទៅប្រាប់សិរីវឌ្ឍសេដ្ឋីនោះថា: . ព្រះករុណាជាអម្ចាស់ជីវិតបង្គាប់ថាឲ្យសេដ្ឋីទឹងអ្នកស្រុកទាំងអស់វេញពួរខ្សាច់ ដើម្បីយកទៅផ្លាស់ពួរចាស់ដែលកណ្ដុរកាត់ បើមិនធ្វើដូចព្រះអង្គបង្គាប់ ទឹងត្រូវទោសជាទម្ងន់ ។ សិរីវឌ្ឍសេដ្ឋី ទឹងពួកមហាជនរកប្រស្នានេះមិនឃើញក៏នាំគ្នាជំរាបដល់ព្រះមហោសថ, ព្រះអង្គរិះគិតដោយប្រាជ្ញាថា មានតែតបប្រស្នាទៅវិញទើបបាន ទើបប្រាប់ថា: អ្នកទាំងអស់កុំភ័យ ចូររកមនុស្សដែលមានសំដីថ្វីមាត់ បាន ៣-៤ នាក់ លុះបានហើយទ្រង់បង្គាប់ថា អ្នកទាំងឡាយចូរទៅក្រាបទូលព្រះរាជាថា: បពិត្រព្រះឧបតីសិរីវឌ្ឍ-សេដ្ឋី ទឹងអ្នកស្រុកទាំងអស់ មិនដឹងវិញពួរខ្សាច់ប៉ុនណាធំឬតូចឡើយ ហេតុនេះសូមព្រះអង្គ ឲ្យពួរខ្សាច់ចាស់ដែលសល់ពីកណ្ដុរកាត់ ទោះតិចក្ដីច្រើនក្ដី យើងខ្ញុំទឹងយកទៅធ្វើជាក្បួន វេញឲ្យដូចពួរចាស់នោះ បើព្រះមហាក្សត្រមានព្រះបន្ទូលថា ប្រស្នងអើយពួរខ្សាច់មិនដែលមានទេ, អ្នកទាំង

អស់គ្នាត្រូវទូលទៀតថា បើពួកខ្លាចអំពីបុរាណមិនមានដូច្នោះ តើហេតុអ្វីក៏ព្រះអង្គ ឲ្យសិរីវឌ្ឍសេដ្ឋី នឹងអ្នកស្រុកវេញពួកខ្លាចដូច្នេះ បុរសទាំងនោះស្តាប់ហើយ ក៏នាំព្រះមហោសថទៅទូលព្រះរាជាតាមបង្គាប់, ព្រះរាជាសួរថា អ្នកណាអាចចេះប្រស្នាតបមកដូច្នេះ បុរសទាំងនោះក្រាបថា គឺព្រះមហោសថ ជាបុត្ររបស់សិរីវឌ្ឍសេដ្ឋី បើខ្ញុំទាំងអស់ឲ្យនាំប្រស្នាមកក្រាបទូល ព្រះរាជាក៏មានព្រះទ័យរីករាយជាគេយ្យាភាព ។

ដល់សម័យក្រោយមកទៀត ព្រះរាជាប្រើរាជអាមាត្យម្នាក់ទៅប្រាប់សិរីវឌ្ឍសេដ្ឋីថា: ព្រះរាជាមានបំណងនឹងស្រង់ទឹកស្រះ ដ្បិតទ្រង់ជ្រាបថា: មហោសថកូនអ្នកបានជីកស្រះធំ មានទឹកថ្លានឹងផ្កាឈូករន្ធាលព្រាលពៅរីកស្គុះស្គាយ ហេតុនេះទ្រង់ឲ្យអ្នកលើកស្រះនោះឲ្យបានទាំងទឹកទាំងឈូក ចាប់ប្រញាប់ទៅថ្វាយ បើអ្នកធ្វើមិនបានតាមបង្គាប់នឹងមានទោសជាទម្ងន់ ។ សិរីវឌ្ឍសេដ្ឋី គិតមិនឃើញទៅសួរព្រះពោធិសត្វ ៗ ពុះហើយក៏ត្រិះរិះថា: មានតែតបប្រស្នាទៅវិញទើបបាន ព្រះអង្គឲ្យរកមនុស្សមានសំដីប៉ូមាត់ច្រើនគ្នាមកដល់ ទ្រង់បង្គាប់ថា: ម្នាលអ្នកទាំងឡាយ ចូរគ្នាយើងទៅលេងទឹកឲ្យមានភ្នែកក្រហម ឲ្យមានសក់ទទឹក មានខ្លួនប្រឡាក់ផុក មានដៃកាន់ព្រត័បុព្វ ដំបងប្រទង់អង្រែ រត់ទៅកាន់ព្រះរាជវាំង ដល់ហើយបង្គំទូលថា: បពិត្រព្រះភូមិន្ទ ព្រះអង្គប្រើរាជអាមាត្យទៅ ឲ្យសិរីវឌ្ឍសេដ្ឋីនាំស្រះមកថ្វាយព្រះអង្គនោះ យើង

ខ្ញុំក៏បានយកព្រ័ត្រទឹងតូចផងក្រៀកទាញមក ស្រះនោះធ្លាប់នៅព្រៃមិន ដែលស្គាល់មនុស្សម្នាមហាជន នឹងរទេះសេះដំរីទេ លុះមកឃើញស្រាប់ តែភ្ញាក់ផ្អើលភ័យបំរះទៅមកៗ ដាច់ព្រ័ត្រតូចខ្ចប់ខ្ចីអស់ ស្ទុះរត់រួចទៅវិញ ឥឡូវនេះយើងខ្ញុំមកសុំស្រះញីមួយអំពីបុកណា ដែលធ្លាប់ថ្នឹកមិនខ្លាច មនុស្ស យកទៅធ្វើជាធ្នាក់ យើងខ្ញុំនឹងនាំស្រះនោះជាមួយនឹងស្រះញីមក ថ្វាយព្រះអង្គ បើព្រះរាជាមានទក្ការថា: អញមិនដែលឮស្រះមានញី ឈ្មោល ហើយយកស្រះញីទៅភក់យកស្រះឈ្មោលដូចសំដីប៉ស្តែង នេះ អ្នកទាំងឡាយត្រូវក្រាបទូលថា: បើព្រះអង្គមានព្រះបន្ទូលថា មិនដែលមានដូច្នេះ ហេតុអ្វីក៏ព្រះអង្គប្រើសិរីវឌ្ឍសេដ្ឋីឲ្យនាំស្រះមក ថ្វាយព្រះអង្គ បើទ្រង់ឲ្យនាំស្រះញីទៅបានៗ ទើបនាំស្រះឈ្មោល មកថ្វាយព្រះអង្គបានៗ ពួកមហាជនក៏ធ្វើតាមបង្គាប់ ហើយទៅឆ្លើយ ប្រស្នាតបនឹងព្រះរាជាតាមព្រះមហោសថ ព្រះរាជាឮហើយក៏សួរថា: អ្នក ណាអាចដោះស្រាយប្រស្នានេះតបមក មហាជនប្រាប់ថាព្រះមហោសថ ប្រើយើងខ្ញុំមកដោះប្រស្នាព្រះអង្គ ព្រះរាជាក៏មានព្រះទ័យត្រេកអរ ក្រៃលែងៗ

ក្នុងសម័យក្រោយមកទៀត ព្រះរាជាប្រើរាជអាមាត្យទៅប្រាប់ សិរីវឌ្ឍសេដ្ឋីថា: ព្រះរាជាមានបំណងនឹងប្រពាធឧទ្យាន ឯឧទ្យាន ព្រះអង្គ មានឈើចាស់ជ្រុះស្លឹកធ្លាក់ចុះអស់ហើយ ហេតុនេះឲ្យអ្នក នាំឧទ្យានថ្មីឲ្យមានឈើធំៗ នឹងផ្ការីកស្គុះស្គាយនាំទៅថ្វាយ បើមិនធ្វើ

តាមបណ្ដាំថានឹងត្រូវមានទោសជាទម្ងន់ ៗ សិរីវឌ្ឍសេដ្ឋីនឹងអ្នកស្រុកទាំងអស់ ក៏ទៅដំរាបព្រះមហោសថៗ ទ្រង់ពិចារណាប្រស្នានេះថា: មានតែអញគិតធ្វើប្រស្នាតបទៅវិញទើបបាន ហើយព្រះអង្គប្រើមហាជនទៅដោះប្រស្នានឹងព្រះរាជា ដូចជាប្រស្នាកន្លងដែលព្រះរាជាឲ្យនាំស្រះ ៗ មហារាជជ្រាបសេចក្ដីសព្វគ្រប់ ក៏មានព្រះរាជហឫទ័យរីករាយយ៉ាងក្រៃលែង ៗ ព្រះរាជាក៏ទ្រង់សួរអាចារ្យសេនកថា: អើ ! លោកអាចារ្យបើដូច្នេះ តើឃើញសមគួរនឹងទៅនាំមហោសថនោះមកទុកជាអ្នកប្រាជ្ញ ឬដូចម្ដេច ? អាចារ្យសេនកក៏ទូលថា: មិនទាន់ល្មមទេ, ព្រោះគិតថាតែមហោសថមកខ្លួននឹងខាតលាភ ព្រះរាជាឮដូច្នោះ ក៏ទ្រង់ព្រះចិន្ដាថា : មហោសថជាអ្នកប្រាជ្ញ អាចដោះប្រស្នាគ្មានទើសទាក់ ហាក់ដូចជាក្មេងមិនមែនអាយុ ៧ ឆ្នាំ ៗ អាចារ្យសេនក មិនឲ្យអញទៅយកមហោសថមកទុកជាអ្នកប្រាជ្ញក្នុងទីនេះ តើព្រោះហេតុអ្វី? បើដូច្នេះអញកុំតាមពាក្យអាចារ្យនេះឡើយ ទ្រង់ព្រះចិន្ដាដូច្នោះហើយ ក៏ស្ដេចឲ្យប្រដាប់ប្រដាព្រះទីនាំង រួចក៏ទ្រង់យាត្រាចេញទៅជាមួយនឹងអាមាត្យសព្វមុខមន្ត្រីសេនាបតីជាដើម ហែហមចេញទៅប៉ុន្ដែពេលនោះសេះមង្គលដែលស្ដេចគង់ជាន់ផុងជើងក្នុងក្រហែងដីគ្រេប ស្ដេចក៏ខានយាងទៅ ហើយវិលមកកាន់ព្រះរាជវាំងវិញ ៗ អាចារ្យទាំង ៤ ដឹងហេតុដូច្នោះក៏ឡើងទៅទូលថា: បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គ ឮថាព្រះអង្គយាត្រាទៅយកមហោសថមែនឬ ? ព្រះរាជាមានព្រះឱង្ការថា

មែន ៗ អាចារ្យទាំង ៤ ក្រាបទូលទៀតថា បពិត្រព្រះអង្គ! ហេតុអ្វីព្រះអង្គធ្វើអំពើឥតប្រយោជន៍ដូច្នេះ យើងខ្ញុំបានទូលថាឈប់សិនមិនទាន់ជាអ្វីទេ ឥឡូវនេះ ជើងសេះមង្គលបាក់កើតជាទុក្ខព្រះដំណើរ ៗ ថ្ងៃក្រោយទៀត ព្រះបាទវិទេហរាជ សួរអាចារ្យទាំ ៤ ដូចមុនទៀត អាចារ្យទាំង ៤ ក៏ក្រាបទូលថា សូមព្រះអង្គកុំស្តេចយាងទៅឡើយ សូមប្រើរាជទូតទៅប្រាប់មហោសថថា យើងចេញមកកាន់សំណាក់ចៅឯង ឥឡូវជើងសេះមង្គលយើងបាក់ ចូរសិរីវឌ្ឍសេដ្ឋី នឹងទៅមហោសថរកសេះមង្គលសងវិញ ៗ ទើបទ្រង់ប្រើអាមាត្យឲ្យទៅជំរាបសេដ្ឋី សេដ្ឋីបានដឹងហើយ ក៏រៀបចំដំណើរមានយានជំនិះនឹងបរិវារចូលទៅគាល់ព្រះរាជា, សិរីវឌ្ឍសេដ្ឋីចូលទៅដល់មុន ឯព្រះមហោសថកុមារ ក៏បង្គាប់ឲ្យបរិវារចាប់មេលាកណ្តៀតដើរតាមក្រោយ, លុះទៅដល់ព្រះបរមរាជវាំង សេដ្ឋីឃើញហើយក៏ក្រោកចេញទៅ ព្រះមហោសថកុមារក៏អង្គុយត្រង់កន្លែងនោះ ៗ ចំណែកអាចារ្យទាំង ៤ នាក់ឃើញដូច្នោះ ក៏សើចគ្អាក ៗ ថាមើល ៗ អ្នកប្រាជ្ញ ៗ ពេលនោះព្រះរាជាទ្រង់ស្រពោនព្រះភ័ក្ត្រខ្លាំង ប៉ុន្តែព្រះមហោសថក្រាបទូលថា: សូមទ្រង់មេត្តាប្រោះមេលានេះជាមេសេះអស្សតរមិនបានឬ? ព្រះរាជាត្រាស់ថា: បានដែរចៅអ្នកប្រាជ្ញ ប៉ុន្តែថោកជាងសេះអស្សតរណាចៅ ៗ បពិត្រព្រះសមតិទេព ឪពុកនឹងកូនណាប្រសើរជាងណា? បើឪពុកប្រសើរជាង លាមេះនឹងថ្លៃជាងសេះអស្សតរ ៗ ព្រោះលានេះជាឪពុកសេះ



អស្សុតរ ប៉ុន្តែមិនមានដំរៀណាជាងសេះអស្សុតរឡើយ ៗ បពិត្រព្រះសម្មតិទេព បើឪពុកប្រសើរជាងកូនសូមព្រះអង្គយកឪពុកខ្ញុំព្រះអង្គចុះ បើកូនប្រសើរជាងសូមព្រះអង្គយកខ្ញុំព្រះអង្គជាសំណងក៏បាន ៗ ព្រះរាជាស្តាប់ចំឡើយពោធិសត្វដូច្នោះក៏មានព្រះទ័យរីករាយក្រៃពេក ទ្រង់ចាប់

កន្ទួមាសមានក្លិនក្រអូបដោយគន្ធពិដោរមកពាក់លើដៃសិរីវឌ្ឍសេដ្ឋី ប្រ-ទានស្រុកប្រាបីនក្រាមទាំងអស់ ព្រមទាំងទ្រព្យសម្បត្តិច្រើន ហើយតាំងមហោសថកុមារជាព្រះរាជបុត្របុង្សរបស់ព្រះអង្គ ។ សេដ្ឋីក៏ទទួលព្រម ហើយថ្វាយបង្គំលាចេញទៅផ្ទះវិញ ។ ចំណែកពួកមហាជនក៏ឲ្យពរសព្ទសាធុការគ្រប់ ៗ គ្នាថាប្រស្នានេះ អ្នកប្រាជ្ញឆ្លើយពីរោះក្រៃពេក ។

ឯព្រះពោធិសត្វឆ្លើយនេះ មិនមែនមើលងាយឥតដឹងគុណមាតាបិតានោះទេ គ្រាន់តែឆ្លើយឲ្យរួចបំណុលសង់សេះអស្សតរដែលព្រះរាជាឲ្យសង់ប៉ុណ្ណោះ ។

ឯអាចារ្យទាំង ៤ ក៏អាប់មុខជោគទាបតាំងពីពេលនោះរៀងមក ។ ព្រះរាជាទ្រង់ត្រាស់សួរថា ម្នាលកូន, ឯងរក្សាបិតាដោយកិច្ចខាងក្នុង ឬខាងក្រៅស្រួល ? ក្រាបទូលថា សូមបំរើដោយកិច្ចការខាងក្រៅចុះ ព្រោះមានបរិវារច្រើនណាស់ ។ ព្រះរាជាក៏ទ្រង់ព្រះរាជទានផ្ទះមួយដល់មហោសថឲ្យនៅជានិច្ចតទៅ ។

ថ្ងៃមួយព្រះរាជាចង់ល្បងប្រាជ្ញាឲ្យច្បាស់នឹងព្រះនេត្រ ទ្រង់ប្រើអាមាត្យឲ្យយកកែវមណីរតន៍ទៅ លាក់ក្នុងសំបុកក្អែកលើដើមត្នោតមួយដើមក្បែរមាត់ស្រះ មិនឲ្យបុរសដទៃណាមួយដឹងសោះឡើយ កែវមណីរតន៍ក៏ឆ្លុះស្រមោលទៅក្នុងទឹកស្រះ ។ ពួកមហាជនបានឃើញហើយ ក៏នាំគ្នាក្រាបទូលដល់មហាក្សត្រ ព្រះអង្គក៏ឲ្យអាចារ្យទាំង៤នាក់

ទៅរក ៗ អាចារ្យទាំង ៤ ក៏ប្រមូលមនុស្សឲ្យបង្ហូរទឹកក្នុងស្រះនោះចេញ ដល់អស់ទឹកក៏រកមិនឃើញ; ដល់បង្ហូរចូលមកវិញក៏ឃើញស្រមោលនៅក្នុងទឹកទៀត ; អាចារ្យទាំង ៤ ឲ្យមនុស្សយកប្រលែមកកាំងមុខទឹក ហើយបង្ហូរចេញម្ដងទៀត ដល់បង្ហូរអស់ រកមិនឃើញទៀត ៗ ព្រះរាជាត្រាស់សួរទៅព្រះមហោសថ ៗ ក្រាបទូលថា ខ្ញុំព្រះអង្គនឹងរកកែវមណីរតន៍នេះឲ្យឃើញដោយងាយ ៗ ទើបមហោសថឲ្យយកភាជន៍មាបមកដាក់ទឹកឲ្យពេញ ហើយយកទៅដាក់ត្រង់មាត់ស្រះនោះ ដើម្បីឲ្យឃើញជាក់ស្ដែងដល់ព្រះរាជា ដល់ដាក់ទៅ ស្រមោលកែវមណីរតន៍ក៏ចុះមកក្នុងភាជន៍មាសនោះដែរ ទើបទ្រង់ក្រាបទូលព្រះរាជាថា: បពិត្រព្រះអង្គ កែវមណីរតន៍នេះមិនមែននៅក្នុងស្រះនេះទេ បើដូច្នេះតើនៅឯណា ? កែវមណីរតន៍នេះ នៅទីសំបុកក្អែកលើដើមត្នោតឯណោះ ទើបប្រើអាមាត្យឲ្យយកកែវមណីរតន៍នោះមកថ្វាយក្សត្រ ៗ ព្រះរាជាទ្រង់មានព្រះទ័យរីករាយទើបប្រទានកែវមណីមួយត្រណោតដល់ព្រះមហោសថព្រមទាំងបរិវារមួយពាន់នាក់ ៗ ចំណែកអាចារ្យទាំង ៤ នាក់ក៏ខឹងតែអាប់មុខជោកទាបរៀងរៀងដរាបមក ៗ

ព្រះបាទវិទេហរាជ នឹងមហាជនប្បន្ន ប្រាជ្ញាព្រះមហោសថ ដោយប្រស្នាទាំង ១៩ ប្រការដូចរៀបរាប់មកដូច្នេះ ព្រះមហោសថពោធិសត្វក៏បានដោះស្រាយស្រះស្រឡះ គួរជាទីជ្រះថ្លារបស់ព្រះបាទវិទេហរាជពន់ពេក ព្រះអង្គក៏លើកដំកើងថាជាព្រះរាជទិរស យ៉ាងឯក ៗ

អបើកទិរិសំ ក្នុងថ្ងៃមួយជាខាងក្រោយមកទៀត ព្រះរាជាទ្រង់យាងទៅក្រសាលឧទ្យាន ពេលនោះ មានសត្វបក្សីមួយ ចុះពីដើមគរធ្វើក្បាលងក់ងើប ៗ ព្រះរាជាត្រាស់សួរថា: បក្សីនេះ វាធ្វើអ្វី ? ព្រះបរោហិតបរមពោធិសត្វក្រាបទូលថា បក្សីនេះ វាគោរពព្រះអង្គ: ព្រះរាជាក៏មានព្រះហឫទ័យរីករាយនឹងបក្សីនោះ ទ្រង់បង្គាប់ឲ្យអាមាត្យទិញសាច់ឲ្យបក្សីនោះស៊ីតែរាល់ៗថ្ងៃ ដល់ថ្ងៃសីលអាមាត្យរកទិញសាច់មិនបានក៏យកមាសមួយជ្រៀវថ្លៃស្មើនឹងសាច់ ទៅបំពាក់នៅកបក្សីមេ ៗ បានមាសពាក់ហើយក៏គិតថា អញក៏មានមាសពាក់ ព្រះរាជាក៏មានមាសពាក់ដូចគ្នា អញគោរពស្តេចធ្វើអ្វីទៀត ៗ ដល់សម័យខាងក្រោយព្រះរាជាស្តេចយាងទៅដល់ទីនោះ បក្សីកើតមានះក្រអឺត មិនគោរពដូចមុនៗទៀយ ៗ ព្រះអង្គនឹកឆ្ងល់ក៏ទ្រង់សួរព្រះមហាសបកុមារ ៗ ក្រាបទូលថា: សូមទ្រង់មេត្តាប្រោស វាមើលងាយព្រះអង្គ ពីព្រោះអាមាត្យបានបំពាក់មាសឲ្យវា ៗ ស្តេចទ្រង់ខ្ញាល់នឹងបក្សីនោះ ទ្រង់បង្គាប់ឲ្យអាមាត្យបណ្តេញចេញពីទីនោះទៅ បក្សីក៏ដល់នូវសេចក្តីវិនាសណាស់ដោយដំកើងមានះ រង្គឹងប៉ុណ្ណោះឯង ៗ

អបរាគេ ក្នុងកាលជាខាងក្រោយមកទៀត មានមាណពម្នាក់ឈ្មោះ “ បណ្ឌិតមាណព „ បានចូលទៅរៀនវិជ្ជានឹងអាចារ្យទិសាបាមោក្ខ ខំឧត្តស្តង់បំរើអាចារ្យដោយកិច្ចសព្វគ្រប់យ៉ាងហ្មត់ចត់ អាចារ្យស្រឡាញ់ពេញអធ្យាស្រ័យ ក៏រៀបផ្សំផ្គុំមាណពនោះជាមួយនឹង

កូនក្រមុំរបស់ខ្លួនឲ្យជាភរិយា ប៉ុន្តែបណ្ឌិតមាណពនោះមិនព្រមរួបរួមសង្វាសជាមួយនឹងនាងជាភរិយានោះសោះ ពីព្រោះនាងនោះជាស្រីបរិបូណ៌ដោយលក្ខណា ។ សម័យថ្ងៃមួយមាណពនោះ លាឪពុក - ម្ដាយក្មេក ដើម្បីនឹងវិលត្រឡប់ទៅស្រុកកំណើតរបស់ខ្លួនជាមួយនឹងភរិយា លុះដើរតាមផ្លូវឆ្ងាយទៅ ក៏មានសេចក្ដីស្រេកឃ្លានដួនជាប្រទះឃើញដើមឧទុម្ពរមួយដើមនៅក្បែរផ្លូវ មានផ្លែទុំជាច្រើនបណ្ឌិតមាណព ក៏ឡើងបេះបរិភោគតែម្នាក់ឯង ឯនាងជាភរិយា និយាយសុំពីដីទៅថា : អ្នកជាស្វាមីអើយ សូមអ្នកបេះផ្លែទម្លាក់មកឲ្យខ្ញុំបរិភោគផង ! មាណពនោះ ឆ្លើយពីចុងដើមឧទុម្ពរមកថា : ឯងឥតដៃទេឬ ? នាងនោះដឹងថាស្វាមីរបស់ខ្លួនមានចិត្តមិនសប្បុរសនឹងខ្លួនដូច្នោះ នាងក៏ខំប្រឹងប្រែងឡើងបេះផ្លែឧទុម្ពរនោះ លុះកំពុងបរិភោគ ស្រាប់តែបណ្ឌិតមាណពលបសម្រូតចុះមកមុន ហើយយកបន្លាមកស្រាស់គល់រួចរត់បាត់ទៅ ឯនាងភរិយានោះ នៅជាប់លើដើមឧទុម្ពរតែម្នាក់ឯង ។ហេតុតែ នាងនោះជាស្រីមានបុណ្យ ថ្ងៃមួយ ព្រះបាទវិទេហរាជ ស្ដេចយាងទៅក្រសាលព្រៃ បានឃើញនាងនោះហើយ ក៏ទ្រង់ត្រាស់សួរលុះទ្រង់ជ្រាបសេចក្ដីសព្វគ្រប់ហើយ ស្ដេចឲ្យអាមាត្យជាក់នាងពីចុងឧទុម្ពរនោះមក រួចយកទៅអភិសេកជាអគ្គមហេសីឯកលើពួកស្រីស្នំទាំងអស់ ស្ដេចទ្រង់ប្រទាននាមនាងថា " ឧទុម្ពកទេវី " ។



ថ្ងៃក្រោយព្រះរាជាទ្រង់បញ្ជានាងលើកពលរថ ជាមួយនឹងព្រះអគ្គ ដើម្បីត្រួតត្រាមើលពួកកម្មករដែលធ្វើផ្លូវក្នុងព្រះនគរ ឲ្យស្អាតបាត, ស្រាប់តែទ្រង់ឃើញ បណ្ឌិតមាណពកំពុងតែកាន់ចបកាប់ជម្រះស្មៅ

បែកញើសកខេរ នាងក៏ញើញញឹមបិទមាត់ ៗ ព្រះរាជាទ្រង់ទតឃើញ នឹកសង្ស័យក្នុងព្រះរាជហឫទ័យ ក៏ទ្រង់ត្រាស់សួរនាងនោះថា: ចុះនាងឯង សើចអី? នាងទើបក្រាបទូលថា: ខ្ញុំម្ចាស់អស់សំណើចនឹងស្វាមីដើម របស់ខ្ញុំម្ចាស់ទេតើ ៗ ស្ដេចទ្រង់ងាកទៅអាចារ្យសេនក ហើយត្រាស់ សួរថា: ដែលមានដែរឬ? ស្ត្រីនឹងបុរសផ្ទុកខុសឆ្ងាយយ៉ាងហ្នឹង ! អាចារ្យនោះក្រាបទូលបន្ថែមថា សូមព្រះអង្គកុំទ្រង់ជឿសំដីកាឡ-កណ្ណីនេះៗ ព្រះមហាក្សត្រទ្រង់ព្រះពិរោធខ្លាំង ទើបទ្រង់មានព្រះរាជឱង្ការ សួរទៅព្រះមហោសថកុមារវិញ ! ព្រះមហោសថកុមារក៏ក្រាបបង្គំទូលថា ធម្មតាមនុស្សអលក្ស័ត (មនុស្សឥតបុណ្យ) នៅរួមរស់ស្នាជាមួយ នឹងមនុស្សលក្ស័ត (មនុស្សមានបុណ្យ) មិនកើតទេ ខុសឆ្ងាយពីគ្នា លន្ទឹលឡោចផ្ទុយជាដីហើយនឹងមេឃ សូមទ្រង់ជ្រាប ៗ ព្រះរាជា ទ្រង់មានព្រះរាជហឫទ័យរីករាយសោមនស្សនឹងមហោសថ ពាក្យសត្យយ៉ាងក្រៃ លែង ទើបត្រាស់ថា សាធុ ៗ ត្រូវណាស់ ហើយទ្រង់ប្រទានរង្វាន់ជា ច្រើន ៗ ឯនាងឧទុម្ពរាទេវី នាងសូមយកព្រះមហោសថកុមារជា ព្រះអនុជតៅរបស់នាង ៗ

តមកមានសត្វពពែមួយគេវាយបាក់ខ្នង នឹងឆ្កែមួយបាក់ជើងមួយ ទៅនៅដេកជាមួយគ្នាក្បែរកំផែងព្រះបរមរាជវាំង, ស្ដេចទ្រង់យល់ថា សត្វទាំងពីរច្បាស់ជាមិត្រសម្លាញ់នឹងគ្នាហើយ ក៏ទ្រង់ត្រិះជាប្រស្នាឡើង ចោទទៅអាចារ្យទាំង ៤ នាក់ថា: ម្នាលអ្នកប្រាជ្ញទាំងឡាយដ៏ចំរើន

សត្វដែលមានជើង ៧ មានខ្លួនមួយ តើជាសត្វអ្វី? អាចារ្យទាំង ៤ នាក់ គិតមិនឃើញក៏ក្រាបទូលថា ចាំថ្ងៃស្អែកខ្ញុំព្រះអង្គទាំងអស់គ្នានឹងឆ្លើយថ្វាយ ហើយក៏បង្គំលាទៅផ្ទះទាំងអស់គ្នាទៅ ។ លុះទៅដល់ផ្ទះក៏ជជែកគ្នាថា យើងមើលទៅគេប្រស្នានេះមិនឃើញទេមើលទៅ ប្រស្នានេះជ្រៅណាស់ បើដូច្នោះ ត្រូវយើងចូលទៅសុំរៀនពីចៅមហោសថកុមារជួនរួចខ្លួន ហើយក៏នាំគ្នាចូលទៅសុំរៀន ។ ព្រះបរមពោធិសត្វ បង្គាប់ឲ្យអាចារ្យសេនកទន្ទេញថា មេណ្ឌោ ៗ: អាចារ្យ ក៏មិនទន្ទេញថាសុនខោ ៗ, អាចារ្យទេវិនទៈទន្ទេញថា: ឧភោមិត្តា មនាបា ៗ, អាចារ្យបក្កុ ទន្ទេញថា: ឧភោ មំសំ តិណភក្ខាទន្តិ ៗ ។ ដល់ចាំស្ទាត់ហើយ ព្រឹកឡើងក៏នាំគ្នាចូលទៅក្រាបទូលព្រះរាជាតាមចាំ ។ ព្រះអង្គទ្រង់ព្រះសណ្ដាប់មិនដឹងជាសេចក្ដីជាដូចម្ដេច ទើបទ្រង់ត្រាស់សួរមហោសថកុមារ ៗ ក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោសពពែមួយជាក់ខ្លួន, ឆ្កែមួយជាក់ជើងមួយ ជាមិត្តស្មាញនឹងគ្នា ។

ព្រះរាជាក៏ទ្រង់លើកយកបញ្ហាមកសួរទៀតថា: មនុស្សមានទ្រព្យតែគ្មានបញ្ញានឹងអ្នកមានបញ្ញាតែឥតទ្រព្យ តើអ្នកណាប្រសើរជាងណា ?: អាចារ្យសេនកឆ្លើយថា: អ្នកមានទ្រព្យឥតបញ្ញាប្រសើរជាង សូមទ្រង់ជ្រាប ។ ព្រះមហោសថពោធិសត្វក្រាបទូលថា: អ្នកមានបញ្ញាតែឥតទ្រព្យនោះប្រសើរជាង ហើយអាងការសីតឯទៀតមកបញ្ជាក់ផង ព្រះមហាក្សត្រទ្រង់ព្រះសណ្ដាប់ហើយ ក៏រឹងរិតតែមានព្រះរាជហឫទ័យត្រេកអររីករាយក្រៃលែងទៅទៀត ទ្រង់បូជា គោឧសភ ១ ពាន់ ? ជារទេះសេះ

អាផ្ទះទ្រព្យ ១ម៉ឺន នឹងស្រុកសួយ ១៦ ដល់ព្រះបរមពោធិសត្វមហោសថ ក្នុងកាលនោះឯង ។

នាងឧទុម្ពរទេវី ពិចារណាថា: មហោសថអ្នកប្រាជ្ញមានអាយុ១៦ឆ្នាំហើយ ទ្រព្យសម្បត្តិមហោសថប្អូនអញក៏មានច្រើនគួរដែរហើយ ដូច្នេះអញគិតរកប្រពន្ធឱ្យប្អូនអញអេះ! នាងឧទុម្ពរទេវីគិតដូច្នោះហើយ ក៏ឡើងទៅទូលដំណើរនោះដល់ ព្រះបាទវិទេហរាជ ។ ទ្រង់ជ្រាបហើយ ក៏មានព្រះទ័យសោមនស្សត្រេកអរជាតេយ្យភាព ។ ទើបទ្រង់អនុញ្ញាតថា: ភទ្ទេ ម្នាលឧទុម្ពរទេវី ជាអគ្គមហេសីសំឡាញ់! ចូរនាងរកតាមគាប់ចិត្តចុះ ។ ចំណែកឯនាងឧទុម្ពរទេវីលុះស្ដេចអនុញ្ញាតឱ្យហើយ ក៏មានសេចក្ដីត្រេកអរ ទើបថ្វាយបង្គំលាព្រះរាជាត្រឡប់មកវិញ ។ និយាយសារស័ក្ដសេចក្ដីនោះដល់ព្រះមហោសថថា: នឹងទៅរកស្ត្រីក្រមុំម្នាក់យកមកធ្វើជាភរិយាបំរើ ។ ព្រះពោធិសត្វឮដូច្នោះហើយគិតថា: បើឱ្យនាងឧទុម្ពរទេវីទៅរកប្រពន្ធមកឱ្យអញ! ដឹងជាគាប់ចិត្តឬមិនគាប់ចិត្ត បើដូច្នេះមានតែអញដើរទៅរកខ្លួនឯងវិញទើបស្រួល: គិតហើយក៏ឆ្លើយថា: បពិត្រព្រះនាងទេវី បើដូច្នោះកុំព្រួយបារម្ភអ្វី រឿងនេះស្រេចតែលើខ្ញុំចុះ ។ នាងបានស្ដាប់ពាក្យមហោសថថាដូច្នោះហើយ ក៏និយាយថា: បើដូច្នោះប្អូនចូរទៅរកខ្លួនឯងចុះ ។ ពោធិសត្វក៏លានាង ទៅកាន់ផ្ទះខ្លួនដល់ហើយប្រាប់រឿងហេតុនោះដល់បរិវារទាំងឡាយរបស់ខ្លួនតាមដោយដំណើរ (រឿង) លុះប្រាប់រួចហើយក៏ដើរទៅម្នាក់ឯង តាមទ្វារខាងជើងទៅ

ដល់ស្រុកខុត្តរក្រោម កាលនោះមានត្រកូលសេដ្ឋីចាស់ម្នាក់នៅស្រុកនោះ ថយសម្បត្តិជាក្រៃក្រលំបាកវិញ សេដ្ឋីនោះមានកូនក្រមុំម្នាក់ ឈ្មោះនាងអមរា នាងនោះមានប្រាជ្ញា ប្រកបនូវលក្ខណទាំងពួង គ្មានអ្នកណា ១ ប្រាជ្ញាយកជាការយាបានឡើយ ។ ថ្ងៃមួយនាងនោះភ្ញាក់អំពីព្រឹក ចំអិនបបរ ទឹងយកទៅជូនឪពុកនាងទៅឯស្រែ ឆ្អិនហើយក៏ដោះដួសយ៉ាងប្រញាប់រួចដើរទៅតាមផ្លូវ ។ ពេលនោះព្រះមហោសថអ្នកប្រាជ្ញឃើញនាងនោះ ក៏រំពឹងមើលចុះឡើងជាច្រើនលើកច្រើនសារ ឃើញនាងនោះមានលក្ខណគ្រប់គ្រាន់ដូច្នោះហើយ ក៏គិតថា: នាងនេះជាស្រីមានលក្ខណ ហើយនាងមិនទាន់មានប្ដីផង ឯនាងអមរាជាធីតាកូនសេដ្ឋីវិញ ក៏ឃើញព្រះមហោសថដែរ គិតថា: បុរសនេះសុភាពរម្យទម បើបានមកនៅផ្ទះអញៗ អាចបំរើផ្គាប់ចិត្តបាន ។ មហោសថគិតថា: បើទុកជាដឹងថាពុំទាន់មានប្ដី ក៏ត្រូវតែអញសួរល្បងមើល តើនាងមានបញ្ញាឬគ្មាន គិតដូច្នោះហើយ ក៏ក្ដាប់ដៃបង្ហាញទៅនាងអមរានោះ នាងឃើញហើយ ដឹងថា បុរសនេះល្បងប្រាជ្ញាថា ខ្លួនអញមានប្ដីឬ មិនទាន់មាន នាងគិតដូច្នោះហើយក៏លាតនូវត្រង់កន្ទេងនោះ រាដៃបង្ហាញវិញ ព្រះមហោសថដឹងថានាងមានប្រាជ្ញា អាចដោះប្រស្នាបាន ក៏ដើរទៅជិតនាងនោះសួរថា ភទ្រេ ម្នាលនាងក្រមុំ នាងឈ្មោះអ្វី ? នាងនោះឆ្លើយវិញថា អ្នកបង ឈ្មោះនាងខ្ញុំគេកន្លងរំលងទៅហើយ ឥឡូវនេះគ្មានទេ



អំពើនោះគេយកមកជាឈ្មោះនៃខ្ញុំ  នាងប្រាប់នេះជាប្រស្នា  ព្រះមហាសថឮហើយគិតថា:  មនុស្សផងទាំងឡាយដែលមិនចេះស្លាប់នោះគ្មានទេ  លុះគិតដូច្នោះ  ហើយក៏ឆ្លើយថា:  ម្នាលនាងៗ  ឈ្មោះអមរាឬអ្វី?  នាងឆ្លើយថា:  ដូចអ្នកថា:នោះមែន ៗ  ព្រះមហាសថសួរទៀតថា:

នាងយកបបរទៅជូនអ្នកណា? នាងអមរាប្រាប់ថា: បពិត្រអ្នក! ខ្ញុំយកទៅជូនទេវតាដែលរក្សាខ្ញុំពីមុន ។ ព្រះមហោសថគិតថា: ទេវតាដែលរក្សាអំពីមុននោះ គឺម្តាយឪពុក ហើយសួរថា: នាងយកទៅជូនឪពុកម្តាយនាងឬ? នាងថា: ចាសអ្នក ។ ឪពុកនាងធ្វើការអ្វី? ឪពុកខ្ញុំធ្វើការមួយជាពីរ ពោធិសត្វគិតថា: ដែលហៅថាធ្វើការមួយជាពីរនោះ គឺប្រាកដជាភ្ជួរស្រែទើបថា: ឪពុកនាងទៅភ្ជួរស្រែឬ? ចាសអ្នក ។ ឪពុកនាងធ្វើស្រែត្រង់កន្លែងណា? ត្រង់កន្លែងដែលគេទៅហើយមិនមកវិញ ពោធិសត្វគិតថា កន្លែងដែលគេទៅហើយមិនមកវិញនោះគឺព្រៃស្មសានដែលគេដុតខ្មោចមនុស្សផងទាំងឡាយ ហើយថា ឪពុកនាងទៅធ្វើស្រែឯព្រៃស្មសានដែលគេដុតខ្មោចឬ? ចាសអ្នក! ។ នាងត្រឡប់មកឥឡូវនេះវិញឬ? ឬមិនទាន់មកទេ? បពិត្រអ្នក! បើគេមកខ្ញុំពុំបានមកឡើយ បើគេមិនបានមកខ្ញុំនឹងត្រឡប់មកវិញ ។ ពោធិសត្វសួរថា ម្នាលនាង! ឪពុកនាងទៅធ្វើស្រែឯនាយស្ទឹង បើទឹកជន់មកនាងពុំបានមកឡើយ បើទឹកមិនជន់ទើបនាងបានមកដូច្នេះមែនឬ? ចាសអ្នក? ដូច្នេះមែន ។

ព្រះមហោសថនឹងនាងអមរា និយាយឆ្លើយឆ្លងដូច្នេះហើយនាងក៏សរសើរថាបពិត្រអ្នកកំឡោះមានរូបស្រស់មានសំដីពីរោះមានប្រាជ្ញាឆ្លាត សូមពិសារបបរនេះចុះ ។ ពោធិសត្វថា: ម្នាលនាងស្រគំ នាងមានមារយាទល្អ បន្សាប់សំដីនាងពីរោះក្រៃពេកបងនឹងបរិភោគបបរនេះ ។ នាងអមរាក៏ដាក់ឆ្នាំងអំពីសិរសាអង្គុយក្នុងទីនោះជាមួយព្រះពោធិសត្វ ។

នាងអមកផ្លូសបបរមួយចំណែកទុកជូនឪពុក សល់ពីនោះជូនព្រះពោធិសត្វ បរិភោគ ៗ លុះរួចហើយ នាងក៏ជូនស្លាបារីទៀត ៗ ត្រង់កន្លែងនោះ មានដើមពុទ្រាមួយដើមមានផ្លែទុំជាច្រើន នាងក៏ឡើងបេះដាក់ចុះស្រេប ហើយ ពោធិសត្វក៏និយាយទៅថា: ម្នាលនាងប្អូននាងឲ្យផ្លែពុទ្រាមក



បងខ្វះ នាងអមរាក៏និយាយជាប្រស្នាល្បងមើលទៀតថា: បពិត្រអ្នក ! អ្នកចង់ពិសារផ្លែពុទ្រាក្តៅឬ ? ឬផ្លែពុទ្រាត្រជាក់ ? ពោធិសត្វដឹងថានាងល្បងប្រាជ្ញាដូច្នោះ ក៏ធ្វើជាមិនដឹងហើយនិយាយទៅថា: បងចង់ស៊ីផ្លែពុទ្រាក្តៅ: នាងក៏បោះផ្លែពុទ្រាទៅលើដីខ្សាច់ដែលកំពង់ក្តៅ ព្រះពោធិសត្វក៏រើសផ្លែពុទ្រានោះមកផ្លុំដីខ្សាច់ចេញ ហើយបរិភោគទៅ ៗ ទ្រង់និយាយទៅទៀតថា: ម្នាលនាង! ប្អូននាងឲ្យផ្លែពុទ្រាត្រជាក់មកបងស៊ីម្តង, នាងក៏បោះផ្លែពុទ្រាទៅលើស្មៅ ៗ ពោធិសត្វគិតថា: នាងនេះមានប្រាជ្ញាណាស់តើ !, ព្រះអង្គ៏មានព្រះទ័យត្រេកអរសោទរនឹងនាងនោះក្រៃលែង ៗ លុះនាងចុះពីលើដើមពុទ្រាមក ព្រះពោធិសត្វសួរទៀតថា: ម្នាលនាង ផ្ទះនាងនៅត្រង់កន្លែងណា ? បងចង់ទៅស្គាល់! នាងក៏ប្រាប់ថា: បពិត្រអ្នក ផ្ទះខ្ញុំមានដើមល្ហុសពីរ មានផ្ការីកស្គុះស្គាយ ជិតផ្សារលក់ដូរ នៅក្នុងស្រុកឧត្តគ្រាម នាងបង្ហាញផ្លូវពោធិសត្វហើយ ក៏លាពោធិសត្វ យកបាយទៅជូនឪពុកនាងហោង ៗ

ព្រះមហាសបបរមពោធិសត្វ ក៏ដើរទៅរកផ្ទះនាងអមរា តាមសំដីដែលនាងប្រាប់ លុះទៅដល់ហើយក៏ចូលទៅ ៗ ចំណែកម្តាយនាងអមរា ឃើញព្រះពោធិសត្វចូលមកកាន់ផ្ទះដូច្នោះ ក៏ក្រាលកន្ទេល លើកបបរមកជូនពោធិសត្វបរិភោគ ៗ ពោធិសត្វក៏និយាយថា: បពិត្រអ្នកមេ! នាងជាប្អូនស្រីបានឲ្យខ្ញុំបរិភោគរួចហើយ ៗ ម្តាយនាងអមរា

ព្ទូរប្អោះ ក៏ដឹងថា អ្នកនេះមកប្រយោជន៍ដើម្បីបានកូនអញទេតើ! ។ ឯព្រះពោធិសត្វ ដឹងថា: ត្រកូលសេដ្ឋីនេះជាអ្នកខ្សត់ទុគ៌ត ព្រះអង្គក៏និយាយទៅថា: បពិត្រអ្នកមេខ្លួនខ្ញុំនេះបេះផុលសំពត់ដែលដាច់ដាច តើអ្នកមានម្ជុលទេ? ខ្ញុំនឹងផុលជូន ។ ម្តាយនាងអមរាក៏ឆ្លើយថា: ហៃបា! ខ្ញុំគ្មានទ្រព្យអ្វីឈ្នួលអ្នកទេ, ពោធិសត្វថា: ខ្ញុំមិនសុំឈ្នួលទេ ចូរអ្នកយកមកខ្ញុំនឹងផុលជូនអ្នកទទេ ។ ម្តាយនាងអមរា ក៏យកសំពត់ដែលដាច់ដាចមកឲ្យពោធិសត្វផុលឲ្យ ។ លុះរួចហើយ ពោធិសត្វប្រាប់ថា: សូមអ្នកមេប្រាប់ដល់អ្នកស្រុកទាំងអស់ឲ្យដឹងសព្វគ្នា, ម្តាយនាងអមរាក៏ទៅប្រាប់គេឯងអស់ទាំងស្រុក, មនុស្សផងទាំងឡាយក៏យកសំពត់ដែលដាច់ដាចមកជួលពោធិសត្វឲ្យផុលឲ្យ ។ ព្រះពោធិសត្វធ្វើអំពើស៊ីឈ្នួលផ្លូវបេះ ក៏បានមាស ១០០០ ដម្លឹងក្នុងថ្ងៃនោះ ។ ម្តាយនាងអមរាក៏រៀបចំដាំបាយល្ងាច នឹងចំណីអាហារជាច្រើន ។ ឯនាងអមរា លុះល្ងាចហើយ នាងក៏មកអំពីព្រៃជាមួយឪពុក ក្បាលទូលបាច់អុស ចង្កេះកណ្តៀតស្លឹកឈើជាអន្ទក់នឹងបន្លែគ្រប់ប្រការ ។ ព្រះពោធិសត្វនឹងឪពុកម្តាយនាងអមរា បរិភោគភោជនាហាររួចហើយ នាងអមរាក៏យកទឹកមកលាងដៃជើងម្តាយឪពុក នឹងពោធិសត្វរួចទើបនាងបរិភោគខ្លួនឯងជាខាងក្រោយ ។ តមកព្រះពោធិសត្វក៏រៀបមង្គលការនឹងនាងអមរាជាភរិយា ។ លុះកន្លងពីរ-បី-ថ្ងៃព្រះពោធិសត្វចង់ល្បងនាងអមរា ក៏និយាយថា: ម្នាលប្អូនស្រី ចូរនាងយកអង្ករបានកន្ទះនាឡិ

ទៅចំអិនជាបបរទឹងនុំទឹងបាយឲ្យបងរំពាព្រឹក, នាងក៏យកអង្ករ ៣ ស្រិត អង្ករដើមនាងចំអិនបបរ អង្ករកណ្ដាលនាងចំអិនបាយ អង្ករចុងនាងធ្វើនុំ លុះបានស្រេចហើយ ក៏លើកមកជូនពោធិសត្វ ក៏បរិភោគមានរស់ឆ្ងាញ់ពីសារយ៉ាងក្រៃលែង, ប៉ុន្តែនិយាយទៅថា: ម្នាលនាងម្ដេចនាងមិនបេះស្ងដណ្ដាំជូនបង ? ធ្វើឲ្យតែអស់អង្ករ ! ហើយស្ដោះទឹកមាត់ដាក់ក្នុងបបរចាក់ចោលទៅដី, នាងឃើញដូច្នោះក៏មិនខឹងឡើយ នាងនិយាយទៅថា: បពិត្រអ្នក ! បើបបរនេះមិនឆ្ងាញ់ទេ សូមអ្នកអញ្ជើញពីសារនុំវិញ ព្រះពោធិសត្វបរិភោគហើយ ក៏ស្ដីដូចមុនទៀត នាងយកបាយមកជូនទៀត ពោធិសត្វបរិភោគហើយក៏ថា: ដូចមុនទៀត, ហើយស្ដីថា: នាងឯងម្ដេចមិនបេះស្ងដណ្ដាំ ធ្វើឲ្យតែអស់ទ្រព្យអញដូច្នេះ , ហើយទ្រង់ធ្វើដូចជាខឹង យកបាយនុំបបរចាក់លាយជាមួយគ្នាហើយស្រោចពីលើក្បាលនាងប្រឡាក់ពេញទាំងខ្លួន ហើយបណ្ដេញថា: ចូរនាងចុះចេញឲ្យឆ្ងាយទៅ ។ នាងក៏នៅតែមិនខឹង បែរជានិយាយទៅថាបពិត្រអ្នកជាស្វាមី, អ្នកធ្វើដូច្នេះប្រពៃពេកណាស់; ហើយនាងសំពះពោធិសត្វចុះទៅតាមបង្គាប់ ។

ពោធិសត្វដឹងថា: នាងមិនខឹងដូច្នោះហើយ ក៏បន្លឺទៅថាម្នាលនាងចូរនាងមកណេះ, នាងក៏ត្រឡប់មកវិញ, ហើយអង្គុយជិតព្រះពោធិសត្វ ព្រះអង្គក៏ហុចសំពត់កម្ពល ហើយប្រាប់ថា: ចូរនាងទៅងូតទឹកជំរះខ្លួនឲ្យស្អាត ហើយស្លៀកសំពត់កម្ពលនេះ រួចត្រឡប់មកជិត



អញ្ជើញ ៗ នាងក៏ធ្វើតាមបង្គាប់ ៗ រួចហើយព្រះពោធិសត្វយកទ្រព្យដែលគេបាននៅទីនោះក្ដី នាំមកអំពីនាយក្ដី ព្រះអង្គជូនទៅម្ដាយឪពុកនាងអមករាំងអស់ ហើយក៏លាម្ដាយក្មេកឪពុកក្មេក នាំនាងអកមកកាន់លំនៅខ្លួនវិញ ៗ

ព្រះមហោសថ ឲ្យស្បែកជើងទឹងជូនទៅនាងពាក់ នាងក៏ទទួលពាក់ លុះដើរដល់កណ្ដាលវាល នាងដោះជូនទឹងស្បែកជើងចេញ លុះដល់កន្លែងមានទឹក នាងក៏ពាក់ស្បែកជើងដើរ ព្រះពោធិ-

សត្វឃើញដូច្នោះក៏សួរថា: ហេតុអ្វីបានជានាងដើរលើគោកមិនពាក់ស្បែកជើង លុះដើរក្នុងទឹកបានពាក់ដូច្នេះ, នាងឆ្លើយថា: បពិត្រព្រះភស្តា ដើរលើគោកខ្ញុំមើលបន្លាជាដើមឃើញ ឯដើរក្នុងទឹក ឆ្អឹងត្រីឬបន្លាជាដើមខ្ញុំមើលពុំឃើញ ហេតុដូច្នេះហើយបានជាខ្ញុំធ្វើបែបនេះ ។ ព្រះពោធិសត្វឮហើយនឹកថា នាងនេះជាស្រីមានប្រាជ្ញាណាស់តើ ។ លុះដើរទៅដល់ក្នុងព្រៃ នាងយកជួនមកពាក់វិញ ព្រះពោធិសត្វសួរទៀតថា: ម្នាលប្អូនស្រីហេតុអ្វី បានជាដើរកណ្ដាលវាលនាងមិនពាក់ លុះដើរដល់ក្នុងព្រៃម្ប់បាននាងពាក់, នាងឆ្លើយថា: បពិត្រព្រះភស្តា ដើរក្នុងព្រៃម្ប់បានជាខ្ញុំពាក់ ព្រោះខ្លាចក្រែងឈើស្ងួត ឬមែកឈើពុកបាក់មកត្រូវក្បាល! ព្រះពោធិសត្វឮហើយក៏មានព្រះទ័យត្រេកអរក្រៃលែង ហើយក៏នាំនាងចូលទៅក្នុងនគរមិថិលា ។

នៅមានតទៅខ្សែទី ៣

# សៀវភៅដែលមានជាវនៅគេហស្ថាន គីម.គី គីះ

| | | |
|---|---|---|
| ព្រះថោងនាងនាគ . . . | ១ សៀវភៅថ្លៃ | ១០៛០០ |
| ព្រះបទុគោរប់ . . | „ | ១០៛០០ |
| រឿងជ័យសុរិវង្ស ទី ១ ដល់ទី ៤ ចប់ . | „ | ១០៛០០ |
| រឿងនាងពីគណ្ដាប់ . . . | „ | ១០៛០០ |
| ព្រះគោព្រះកែវ ទី ១ ដល់ទី ៧ ចប់ . | „ | ៨៛០០ |
| គេជាដំឌិន ទី ១ ដល់ទី ៧ ចប់ . . | „ | ៨៛០០ |
| ទឹកកំផ្កាកំ ទី ១ ទី ២ ចប់ . . . | „ | ៨៛០០ |
| កាព្យកំសាន្តចិត្ត . . . . | „ | ៦៛០០ |
| រឿងធនូមឿង ទី ១ ទី ២ ចប់ . . | „ | ៨៛០០ |
| រឿងធ្មេញជ័យ . . . . | „ | ១២៛០០ |
| រឿងអាឡាដាំងមនុស្សម្នាក់ទិញចង្កៀងទិព្វ | „ | ១៤៛០០ |
| រឿងព្រះសធន នាងកែវមនោរា ទី ១ ទី ២ ចប់ | „ | ៩៛០០ |
| រឿងកែវឡុងកែវឡាយ ទី ១ ទី ២ ចប់ . | „ | ១១៛០០ |
| ពិម្ពាពិលាប . . . . | „ | ១០៛០០ |
| នានាធម្មសំវេគ . . . . | „ | ៨៛០០ |
| ល្បើកសត្វអក . . . . | „ | ៤៛០០ |
| រឿងតាវឯក ទី ១ ទី ២ ទី ៣ ទី ៤ . | „ | ៤៛០០ |
| សេកសារិកា . . . . | „ | ៧៛០០ |
| រឿងរតនាវង្ស ទី ៦ ទី ៧ ទី ៨ . . | „ | ៥៛០០ |

# សៀវភៅដែលមានជាវនៅគេហស្ថាន គឹម-គី គឹះ

| | | |
|---|---|---|
| សុន្ទរកថា . . . . | ១ សៀវភៅថ្លៃ | ៥៛០០ |
| សម្ភារសិក្ខាបទសុទ្ធុយធម្មវិន័យ | | ១២៛០០ |
| ទេវតាភាសិតនិងពុទ្ធភាសិត . . | ” | ៨៛០០ |
| បកិណ្ណកបរិត . . . . | ” | ១២៛០០ |
| វេយ្យាករណ៍បាថ ទី ១ . . . | ” | ១៨៛០០ |
| ” ” ទី ២ . . . | ” | ១៧៛០០ |
| វេយ្យាករណ៍ខ្មែរ .. . . . | ” | ១៣៛០០ |
| ធម្មសង្គហៈ ភាគ ១ ភាគ ២ . . | ” | ១៥៛០០ |
| បញ្ញាទិទេស . . . . | ” | ២៥៛០០ |
| ប្រស្នាគិហិបដិបត្តិ . . . . | ” | ១៨៛០០ |
| វិធីប្រែបាលី . . . . | ” | ២៥៛០០ |
| ប្រស្នាអភិធម្ម . . . . | ” | ២៥៛០០ |
| ប្រស្នាត្រៃគុណ . . . . | ” | ២៥៛០០ |
| សាមណេរវិន័យបញ្ហា . . . | ” | ១៨៛០០ |

## សៀវភៅកំពុងបោះពុម្ពតទៅ

រឿងដំបងក្រញូង - ក្អែកក - បក្សីចាំក្រុង  រឿងចម្ប៉ាថោងចិញ្ចឹមក្រពើ

រឿងវិបុលសង្គ្រាម  រឿងព្រះបាទអជាតសត្រូវ

រឿងសុវណ្ណកីណា  រឿងនិទានទេវទត្ត

រឿងព្រះសុវណ្ណវង្ស  រឿងខ្យងសាំង

និងសៀវភៅ បារាំង ខ្មែរ ដទៃទៀតជាច្រើន

ការផ្សាយរបស់

លេខ ៨៨ វិថីអេមេក្រង់ ភ្នំពេញ

ជិតពេទ្យកុនព្រហ្មបាយ័នផាល់

រក្សាសិទ្ធិ

បណ្ណាល័យ
សាលអា
ខ. ៩៥
ទទួលថ្ងៃទី ១៩

រោងពុម្ពអាស្យាទិច
ភ្នំពេញ